**ព្រះរាជាណាចក្រកម្ពុជា**
Kingdom of Cambodia

**ជាតិ សាសនា ព្រះមហាក្សត្រ**
Nation Religion King

**រាជរដ្ឋាភិបាលកម្ពុជា**
Royal Government of Camboida
លេខ : ៤២ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការបង្កើតអគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាធម្មនុញ្ញ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្ម នុញ្ញ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ជស.រកម.០៤៩៨.០៦ ចុះថ្ងៃទី ១៩/០៣/៩៨
- យោងតាមសំណើរបស់ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ

## សំរេច

**មាត្រា១**: ត្រូវបានបង្កើតអគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាធម្មនុញ្ញស្ថិតក្រោមអំណាចប្រធានក្រុមប្រឹក្សាធម្មនុញ្ញ

អោយទទួលបន្ទុករៀបចំចាត់ចែងការងារ ធ្វើកំណត់ហេតុ ទទួលរ៉ាប់រងផងដែរ នូវគ្រប់កិច្ចការរដ្ឋបាលរបស់ក្រុមប្រឹក្សាធម្មនុញ្ញ។

**មាត្រា២:** អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ ដឹកនាំដោយអគ្គលេខាធិការមួយរូប អគ្គលេខាធិការរងមួយរូបជាអ្នកជំនួយការ នៅក្រោមការទទួលខុសត្រូវរបស់ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ។ អគ្គលេខាធិការដឹកនាំបញ្ជាការងាររដ្ឋបាលក្រុមប្រឹក្សាធម្មនុញ្ញ។ អគ្គលេខាធិការ អាចទទួលសិទ្ធិពីប្រធាន ដើម្បីចុះហត្ថលេខា លើលិខិតឬ សេចក្តីសំរេចរដ្ឋបាល។ អគ្គលេខាធិការ និង អគ្គលេខាធិការរង ត្រូវ ជ្រើសរើសក្នុងចំណោមមន្ត្រីជាន់ខ្ពស់ មានបទពិសោធន៍ក្នុងកិច្ចការរដ្ឋបាលយ៉ាងតិច ១០ឆ្នាំ ហើយដែល មិនមែនជាសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ និង មិនមែនជាអ្នកដឹកនាំក្នុងគណបក្សនយោបាយណាមួយ។

**មាត្រា៣:** អគ្គលេខាធិការ និង អគ្គលេខាធិការរង ត្រូវតែងតាំងដោយព្រះរាជក្រឹត្យ តាមសេចក្តីស្នើសុំរបស់ក្រុម-ប្រឹក្សាធម្មនុញ្ញ ក្រោយពីបានពិគ្រោះយោបល់ជាមួយសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ដែលមានវត្តមាន ។ អគ្គលេខាធិការ និង អគ្គលេខាធិការរង មានឋានៈស្មើនឹង រដ្ឋលេខាធិការ និង អនុរដ្ឋលេខាធិការ។

**មាត្រា៤:** អគ្គលេខាធិការដ្ឋាន ត្រូវចែកជានាយកដ្ឋានរដ្ឋបាល-ហិរញ្ញកិច្ច និង នាយកដ្ឋានច្បាប់វិវាទកម្ម និង ស្រាវជ្រាវ។ នាយកដ្ឋានចែកជាការិយាល័យ។

នៅក្នុងក្របខណ្ឌឥណទាន ដែលបើកអោយចាយសំរាប់ការប្រព្រឹត្តទៅ នៃក្រុមប្រឹក្សាធម្មនុញ្ញប្រធានក្រុមប្រឹក្សាធម្មនុញ្ញត្រូវជ្រើសរើស តែងតាំងបុគ្គលិកទាំងអស់ នៃអគ្គលេខាធិការ ដ្ឋានតាមសំណើរបស់អគ្គលេខាធិការ។

បុគ្គលិកទាំងអស់ អាចជ្រើសរើសថ្មី ឬ ផ្ទេរពីស្ថាប័នរដ្ឋផ្សេងៗទៀតក៏បាន។ មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាធម្មនុញ្ញ មានប្រាក់បៀវត្ស និង ប្រាក់ឧបត្ថម្ភផ្សេងៗទៀតស្មើនឹងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានរដ្ឋសភា។

**មាត្រា៥:** ចំណាយសំរាប់ការប្រព្រឹត្តទៅ នៃក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវធ្វើអាណត្តិបើកប្រាក់ ដោយប្រធានក្រុមប្រឹក្សាធម្មនុញ្ញ។ ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ អាចផ្ទេរសិទ្ធិនេះខ្លះ ជូនអគ្គលេខាធិការជាអាណាប័កផ្ទេរសិទ្ធិ។

គណនេយ្យករម្នាក់ត្រូវបានតែងតាំង ដោយប្រធានក្រុមប្រឹក្សាធម្មនុញ្ញ អោយទទួលបន្ទុកបើកអាណត្តិបើកប្រាក់។

**មាត្រា៦:** កំណត់ហេតុទាំងអស់ និង ឯកសារដ៏ទៃទៀតរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវរក្សាទុកនៅក្នុង អគ្គលេខាធិការដ្ឋាន ហើយមិនត្រូវធ្វើអោយបែកខ្ចរខ្ចាយទៅខាងក្រៅ ដោយគ្មានការអនុញ្ញាត ពីប្រធានឡើយ។

**មាត្រា៧:** បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៨:** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រុមប្រឹក្សាធម្មនុញ្ញ និង រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០១ ខែ កក្កដា ឆ្នាំ ១៩៩៨

| **នាយករដ្ឋមន្ត្រីទី ១** | **នាយករដ្ឋមន្ត្រីទី ២** |
|---|---|
| ហត្ថលេខា | ហត្ថលេខា |
| **អ៊ឹង ហួត** | **ហ៊ុន សែន** |

កន្លែងទទួល:

- ខុទ្ទកាល័យព្រះមហាក្សត្រ
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យឯកឧត្តមនាយករដ្ឋមន្ត្រីទី ១
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រីទី ២
- ដូចមាត្រា ៨
- ឯកសារ-កាលប្បវត្តិ